

ACLEDA E-COMMERCE

អេស៊ីលីដា

# អ៊ីខុមមើស

ជម្រើសដ៏ងាយស្រួលសម្រាប់លក់
ទំនិញ-សេវាកម្ម តាមប្រព័ន្ធអ៊ីនធើណែត

សម្រាប់ព័ត៌មានបន្ថែម សូមស្កេនទីនេះ


សម្រាប់តម្រូវការប្រើប្រាស់សេវាធនាគារ និងព័ត៌មានផ្សេងៗទៀត
សូមទាក់ទងការិយាល័យទំនាក់ទំនងអតិថិជន ២៤ម៉ោង

+855 (0)23 994 444
+855 (0)15 999 233

អ៊ីម៉ែល: inquiry@acledabank.com.kh
វេបសាយ: www.acledabank.com.kh


អេស៊ីលីដា ACLEDA BANK

# អេស៊ីលីដាអ៊ីខុមមើស

អេស៊ីលីដាអ៊ីខុមមើសជាមធ្យោបាយ/ទូទាត់ ទំនិញ-សេវាកម្មផ្សេងៗ តាមអនឡាញអតិថិជនអាចទិញ-ទូទាត់បានយ៉ាងឆាប់រហ័ស ។

## អត្ថប្រយោជន៍

### សម្រាប់អតិថិជនប្រើប្រាស់ប័ណ្ណ ឬម្ចាស់គណនី

- អាចបញ្ជាទិញទំនិញ-សេវាកម្ម តាមរយៈគេហទំព័រលក់ទំនិញ-សេវាកម្ម ដែលភ្ជាប់សេវាអ៊ីខុមមើសគ្រប់ពេលវេលា
- ងាយស្រួលក្នុងការទូទាត់ និងទទួលបានទំនិញដល់គេហដ្ឋាន ឬទីតាំងកំណត់តាមការព្រមព្រៀង
- អាចទូទាត់ថ្លៃទំនិញតាមរយៈព័ត៌មានរបស់ប័ណ្ណឥណពន្ធ/ប័ណ្ណឥណទាន ឬគណនី និងមិនចាំបាច់បង្ហាញប័ណ្ណដល់អ្នកផ្គត់ផ្គង់
- ចំណេញពេលវេលា និងមានសុវត្ថិភាពខ្ពស់ក្នុងការទូទាត់ទំនិញ-សេវាកម្មអនឡាញ ដោយពុំចាំបាច់ចំណាយពេលវេលាទៅកាន់ទីតាំងផ្ទាល់របស់អ្នកផ្គត់ផ្គង់

### សម្រាប់អ្នកលក់ទំនិញ-សេវាកម្ម

- មានឱកាសទទួលប្រាក់ចំណេញកាន់តែច្រើនពីការលក់ផលិតផល
  - សេវាកម្មថ្មីៗតាមប្រព័ន្ធអ៊ីនធើណែត
- មានកេរ្តិ៍ឈ្មោះល្អ និងទទួលបានអតិថិជនគ្រប់ទិសទីតាមរយៈការលក់ទំនិញ
  - សេវាកម្មអនឡាញ
- បម្រើសេវាបានរហ័ស និងងាយស្រួលគ្រប់គ្រងសាច់ប្រាក់តាមរយៈភាពជាដៃគូ ជាមួយធនាគារ អេស៊ីលីដា ក្នុងការប្រមូលប្រាក់ថ្លៃទំនិញ
- បន្ថយចំណាយក្នុងការជួល ឬបង្កើតហាងលក់ទំនិញ និងបញ្ជូរបង់ប្រាក់ជំនួសដោយការលក់ទំនិញ-សេវាកម្មអនឡាញស្ទើរតែទាំងស្រុង
- កាត់បន្ថយហានិភ័យក្នុងការទទួលក្រដាសប្រាក់ក្លែងក្លាយ ការរាប់ក្រដាសប្រាក់ដែលមានបញ្ហាលើស-ខ្វះជាដើម
- អាចត្រួតពិនិត្យរបាយការណ៍ និងតាមដានការបង់ប្រាក់មានប្រសិទ្ធភាពខ្ពស់ តាមរយៈការទាញយករបាយការណ៍ភ្លាមៗ ពីប្រព័ន្ធ



### លក្ខណៈសម្បត្តិរបស់ពាណិជ្ជករដែលជាម្ចាស់វេបសាយលក់ទំនិញ-សេវាកម្ម

ដើម្បីអាចប្រើប្រាស់សេវាអេស៊ីលីដាអ៊ីខុមមើស ពាណិជ្ជករដែលជាម្ចាស់វេបសាយលក់ទំនិញ-សេវាកម្មត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

- មានគណនីជាមួយធនាគារ អេស៊ីលីដា ។
- មានវេបសាយសម្រាប់លក់ទំនិញ ឬសេវាកម្ម ។
- មានឈ្មោះ និងពាណិជ្ជសញ្ញា (Logo) របស់ក្រុមហ៊ុន/អង្គភាព ។
- មានរូបភាពទំនិញ និងលក្ខណៈពិសេសរបស់ទំនិញ ឬសេវាកម្មដែលសម្រាប់លក់ជូនអតិថិជន ។
- ត្រូវចេញវិក្កយបត្រអេឡិចត្រូនិកជូនអតិថិជន ។
- មាននីតិវិធីប្រគល់ទំនិញច្បាស់លាស់ ដូចជា របៀប/ពេលវេលាប្រគល់ទំនិញ ប្រទេស/តំបន់ដែលអាចដឹកជញ្ជូនទំនិញដល់ឬមិនដល់ ។ល។

## ការដាក់ពាក្យស្នើសុំសេវាអេស៊ីលីដាអ៊ីខុមមើស

អតិថិជនដែលជាពាណិជ្ជករត្រូវអញ្ជើញមកការិយាល័យសាខារបស់ ធនាគារ អេស៊ីលីដា ដោយភ្ជាប់មកជាមួយនូវឯកសារតម្រូវ ៖ ឯកសារសម្គាល់អត្តសញ្ញាណរបស់ម្ចាស់គណនី នាយក ភាគទុនិក ឬដៃគូ, អនុស្សរណៈ និងលក្ខន្តិកៈ, វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម, លិខិតអនុញ្ញាត អាជីវកម្មឬឱ្យដំណើរការអង្គភាព ។ល។

### សុវត្ថិភាពខ្ពស់

រាល់ពេលទូទាត់ទំនិញ-សេវាកម្មអនឡាញ អតិថិជនត្រូវបញ្ចូលទៅក្នុងប្រព័ន្ធនូវលេខកូដផ្ទៀងផ្ទាត់ (3Ds Secure Code) ដែលផ្ញើសារទៅកាន់ទូរស័ព្ទដៃផ្ទាល់ ឬតូកិន (Token) ដើម្បីបញ្ជាក់បន្ថែមលើការទូទាត់ ។

